ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៩.......សហវ.......

ថ្ងៃសុក្រ ៥រោច ខែស្រាពណ៍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែសីហា ឆ្នាំ២០២១

**សេចក្តីជូនដំណឹង**
**ស្តីពី**
**ការដាក់ឱ្យប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ**
**ដំណាក់កាលទី២ ជំហានទី១ នៅរដ្ឋបាលរាជធានី ខេត្ត**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានបង្កើតប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ (Non-Tax Revenue Management Information System - NRMIS) ដែលបានដាក់ឱ្យអនុវត្តជាផ្លូវការក្នុងដំណាកក់កាលទី១ ជំហានទី១ ទី២ និងទី៣ នៅរដ្ឋបាលកណ្តាលក្រសួង ស្ថាប័នចំនួន ២៣ និងមន្ទីរ អង្គភាពជំនាញចំនួន១៨ នៅរាជធានី ខេត្ត កន្លងរួចមកហើយ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធ NRMIS ទៅដល់រដ្ឋបាលរាជធានី ខេត្ត នៅដំណាក់កាលទី២ ជំហានទី១ សម្រាប់រដ្ឋបាលរាជធានីភ្នំពេញ ចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ និងរដ្ឋបាលខេត្តទូទាំងប្រទេស ចាប់ពីថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២១ តទៅ។

ដើម្បីឱ្យប្រព័ន្ធនេះដំណើរការបានរលូន ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងនិរន្តរភាព ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសូមជម្រាបជូនដំណឹងដល់ធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាបដូចតទៅ÷

ក. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានតម្រូវឱ្យរដ្ឋបាលរាជធានី ខេត្ត ប្រើប្រាស់វិក្កយបត្រដែលមានលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ, ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត)។

ខ. នៅដំណាក់កាលទី២ ជំហានទី១ រដ្ឋបាលរាជធានី ខេត្ត ទូទាំងប្រទេស នឹងត្រូវអនុវត្តការកត់ត្រា និងបង់ចំណូលតាមរយៈប្រព័ន្ធ NRMIS ។

គ. បេឡាករ នៃធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ ត្រូវបញ្ចូលលេខ វិក្កយបត្រ ដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ទៅក្នុងបង្កាន់ដៃបង់ប្រាក់ (កន្លែងបរិយាយ/អត្ថន័យ នៃការបង់ចំណូល) ដើម្បីផ្តល់ភាពងាយស្រួលក្នុងការផ្ទៀងផ្ទាត់ប្រភពចំណូលជាមួយរដ្ឋបាលរាជធានី ខេត្ត ។

ឃ. ក្នុងករណីដែលចំណូលមិនមែនសារពើពន្ធទាំងឡាយណាពុំមានកំណត់លេខកូដទេនោះ រដ្ឋបាលរាជធានី ខេត្ត ពុំអាចបង់ចំណូលទាំងនោះបានឡើយ ហើយត្រូវស្នើសុំតាមរយៈអគ្គនាយកដ្ឋានរដ្ឋបាល ឬ អគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ នៃក្រសួងមហាផ្ទៃ មកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (អគ្គនាយកដ្ឋានរតនាគារជាតិ ឬ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ) ដើម្បីពិនិត្យ និងអនុម័តលេខកូដជូន។

ង. ចំពោះចំណូលពីសេវាសាធារណៈ អតិថិជន ឬ រដ្ឋបាលរាជធានី ខេត្ត មិនអាចបង់សាច់ប្រាក់ចូលគណនីចរន្តរបស់រតនាគាររាជធានី ខេត្ត នៅធនាគារពាណិជ្ជដៃគូ តិចជាង ឬ ច្រើនជាង ទឹកប្រាក់នៅលើវិក្កយបត្រដែលបានបោះពុម្ពចេញពីប្រព័ន្ធ NRMIS ឡើយ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ: (+៨៥៥)២៣ ៨៩០ ៦៦៦
Phone: (+855) 23 890 666

ការរៀបចំលេខកូដសម្រាប់បង់ចំណូលមិនមែនសារពើពន្ធ (ចំណូលពីសេវាសាធារណៈ ចំណូលពីទ្រព្យសម្បត្តិរដ្ឋ និងចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត) សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវបានកំណត់ជាទម្រង់ ដូចខាងក្រោម÷

**ក. ចំណូលមុខងារផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត**

១. ចំណូលសេវារដ្ឋបាល (សេវារដ្ឋបាលផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត) ÷ **9XX-TT-9999**

២. ចំណូលក្រៅពីសេវារដ្ឋបាល (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ ចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត និងចំណូលពីពិន័យផ្សេងៗ) ÷ **9XX-PP-TT-9999**។

**ខ. ចំណូលដែលបានធ្វើប្រតិភូកម្ម ឬ ប្រគល់មុខងារ ពីក្រសួង ស្ថាប័ន របស់រដ្ឋបាលរាជធានី ខេត្ត**

១. ចំណូលសេវាសាធារណៈ (សេវាដែលបានធ្វើប្រតិភូកម្ម ឬ ប្រគល់មុខងារ ពីក្រសួង ស្ថាប័ន) ÷ **9XX-MMM-TT-9999**

**២.** ចំណូលក្រៅពីសេវាសាធារណៈ (ចំណូលពីទ្រព្យសម្បត្តិរដ្ឋ ចំណូលមិនមែនសារពើពន្ធផ្សេងៗទៀត និងចំណូលពីពិន័យផ្សេងៗ) ÷ **9XX-PP-MMM-TT-9999**។

❖ ***កំណត់សំគាល់*** (TT) ÷

ក. ផ្នែកកូដចំណូលពីសេវាសាធារណៈ លេខ 01

ខ. ផ្នែកកូដចំណូលពីទ្រព្យសម្បត្តិរដ្ឋ ÷ 02 ការជួល, 03 ភាគលាភ, 04 ចំណូលពីកាតព្វកិច្ចកាស៊ីណូ, 05 សម្បទាន, 06 ផលនេសាទ, 07 ចំណូលពីអាកាសចរស៊ីវិល, 08 ផ្សេងៗ, 09 ពិន័យ និង 10 ចំណូលពីកាតព្វកិច្ចឆ្នោត។

- XX : 01 សម្គាល់រាជធានី ខេត្ត, 02 សម្គាល់ក្រុង ស្រុក ខណ្ឌ និង 03 សម្គាល់ឃុំ សង្កាត់
- PP : កូដសម្គាល់ភូមិសាស្ត្ររដ្ឋបាលរាជធានី ខេត្ត
- MMM : កូដក្រសួង ស្ថាប័នដែលធ្វើប្រតិភូកម្ម ឬ ប្រគល់មុខងារ
- TT : ប្រភេទចំណូល
- 9999 : លេខរៀងចំណូល។

➢ <u>ឧទាហរណ៍ទី១</u> ÷ ចំណូលពីសេវាសាធារណៈផ្ទាល់របស់រដ្ឋបាលរាជធានី ខេត្ត

**សេចក្ដីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 901010001។

- 901 = សម្គាល់ចំណូលរបស់រាជធានី ខេត្ត
- 01 = សម្គាល់ប្រភេទចំណូលពីសេវាសាធារណៈ
- 0001 = សម្គាល់លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)។

*ខ្លឹមសារ÷ ការបញ្ជាក់លើឯកសារថតចម្លង សេចក្ដីអនុញ្ញាតឱ្យប្រកបអាជីវកម្ម អាហារ៍ណ នីហរ៍ណ សណ្ឋាគារ វិនិយោគទុនបរទេស។*

➢ <u>ឧទាហរណ៍ទី២</u> ÷ ចំណូលពីសេវាសាធារណៈដែលបានធ្វើប្រតិភូកម្ម ឬ ផ្ទេរធនធានពីក្រសួង ស្ថាប័ន (មន្ទីរសុខាភិបាល) ជូនរដ្ឋបាលរាជធានី ខេត្ត

**សេចក្ដីពន្យល់÷ <u>ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷</u>** 901120010001។

- 901 = សម្គាល់ចំណូលរបស់រាជធានី ខេត្ត
- 120 = សម្គាល់មន្ទីរសុខាភិបាល
- 01 = សម្គាល់ប្រភេទចំណូលពីសេវាសាធារណៈ
- 0001 = សម្គាល់លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)។

*ខ្លឹមសារ÷ ការផ្ដល់លិខិតអនុញ្ញាតប្ដូរទីតាំងអគារឱសថបុរាណ។*

- ឧទាហរណ៍ទី៣÷ ចំណូលពីទ្រព្យសម្បត្តិរដ្ឋរបស់រដ្ឋបាលរាជធានីភ្នំពេញ÷

**សេចក្តីពន្យល់÷ ឧទាហរណ៍ពីការបង់ចំណូលនៅធនាគារ÷** 90112020001។

- 901 = សម្គាល់ចំណូលរបស់រាជធានី ខេត្ត
- 12 = សម្គាល់រាជធានីភ្នំពេញ
- 02 = សម្គាល់ប្រភេទចំណូលពីការជួល
- 0001 = សម្គាល់លេខរៀងចំណូលពីសេវាសាធារណៈ (លេខរៀងទី ១)។

*ខ្លឹមសារ÷ ក្រុមហ៊ុន L.A.S VISION ជួលតូបនៅផ្សាររាត្រី។*

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមធនាគារពាណិជ្ជដៃគូ និងគ្រឹះស្ថានហិរញ្ញវត្ថុដៃគូ មេត្តាជ្រាប និងផ្តល់កិច្ចសហការអនុវត្តប្រកបដោយប្រសិទ្ធភាព។

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន÷**
- ធនាគារជាតិនៃកម្ពុជា
- ធនាគារ កម្ពុជាសាធារណៈ ភីអិលស៊ី
- ធនាគារ អេស៊ីលីដា ភីអិលស៊ី
- ធនាគារ កាណាឌីយ៉ា ក.អ
- ធនាគារ ឯកទេសវីង (ខេមបូឌា) លីមីធីត
- ធនាគារ វឌ្ឍនៈ
- ធនាគារ ជេ ត្រាស់ រ៉ូយ៉ាល់
- ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
- គ្រឹះស្ថានហិរញ្ញវត្ថុដៃគូ "ដើម្បីសហការអនុវត្ត"
- ឯកសារ-កាលប្បវត្តិ